# សណ្ដែកសៀង



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី

(ADB) លេខ 1445 - CAM (SF)

ឆ្នាំ ២០០៥

# សណ្តែកសៀង

ម.ព.ឯ.ក AIDOC
Code: 248-043
Date:
Donated by:



## I- ស្ថានភាពទូទៅ

សណ្តែកសៀងជាប្រភេទដំណាំដែលមានអាយុចំណាស់ តាមបុរេប្រវត្តិបានឱ្យដឹងថា វាមានប្រភពនៅក្នុងតំបន់ខាងកើត នៃភូមិភាគខាងជើងប្រទេសចិន ហើយត្រូវបានគេប្រើប្រាស់នៅតំបន់នោះ ក្រោយមកវាត្រូវបាន រីករាលដាលដល់តំបន់អាស៊ីបាស៊ីហ្វិច និងទ្វីបអាមេរិក ។

សណ្តែកសៀងប្រភេទនេះស្ថិតនៅក្នុងគ្រួសារ Legumino Sae ឈ្មោះវិទ្យា-សាស្ត្រថា Glycinemax Merr ឈ្មោះធម្មតា Soy bean ។

ផលិតផលសណ្តែកសៀង ត្រូវបានគេយកទៅកែច្នៃផលិតចេញជាម្ហូបអាហារ ព្រមទាំងឱសថ ។ល។ តាមការវិភាគរបស់វិទ្យាស្ថានដំណាំបន្លែ អាស៊ីនិង (AVRDC) និងវិទ្យាស្ថានអន្តរជាតិស្តីពីដំណាំ Legum ICRISAT ឥណ្ឌាបានរកឃើញអត្ថប្រយោជន៍ ផ្នែកម្ហូបអាហារ ដែលមានសារធាតុចិញ្ចឹមក្នុងទំងន់ ១០០ ក្រាមគ្រាប់ស្ងួតអាចបរិភោគបាន ដូចក្នុងតារាងខាងក្រោម :

## តារាងអាហាររូបត្ថម្ភក្នុងទំងន់ ១០០ ក្រាម បរិភោគបាន

| ទំងន់១០០ក្រាម | ជាតិទឹក | ប្រូតេអ៊ីន | ប្រេង | កាបូអ៊ីដ្រាត | ជាតិផេះ | ថាមពល |
|---|---|---|---|---|---|---|
| | G | G | G | G | G | G |
| | ១០ | ៣៥ | ១៨ | ៣២ | ៥ | ១៦៨០ |

AVRDC 1985

## II - បច្ចេកទេសដាំដុះ

### ១- ការជ្រើសរើសពូជ



សណ្តែកសៀងជាដំណាំ ដែលអាចលូតលាស់បានស្ទើរគ្រប់រដូវនៅក្នុងតំបន់ដែលមានអាកាសធាតុក្តៅ វាជាដំណាំមិនប្រកាន់រដូវ ។ សណ្តែកសៀងមាន ២ក្រុម គឺក្រុមលូតលាស់កំណត់ និងក្រុមលូតលាស់មិនកំណត់ ។

- ពូជលូតលាស់កំណត់ : ភាគច្រើន អាយុកាលលូតលាស់ខ្លី បែកមែកមធ្យម កំពស់ដើមពី ៤៥-៧០ស.ម ថ្នាំងញឹក ផ្លែនៅតាមថ្នាំងនៃដើមច្រើនជាងមែក ដើមរឹងមិន

ដួល ទុំមិនប្រេះជ្រុះគ្រាប់ ។

- ពូជលូតលាស់មិនកំណត់ : ភាគច្រើនជាពូជអាយុកាលវែងបែកមែកច្រើន ថ្នាំងរង្វើល ស្លឹកធំខ្ចី ដើមខ្ពស់ លក្ខណៈជាវល្លិ ផ្លែច្រើននៅតាមមែកហើយរង្វើល ។ ពូជសណ្តែកសៀងចែកចេញជា ៣ប្រភេទដូចជាពូជស្រាល ៦៥-៨៥ ថ្ងៃ ពូជកណ្តាលពី ៨៥-១២០ថ្ងៃ និងពូជធ្ងន់ ១៥០ ថ្ងៃឡើងទៅ ។ ការជ្រើសរើសពូជសណ្តែកសៀងសំរាប់ដាំដុះនៅប្រទេសកម្ពុជាយើងគឺជាប្រភេទពូជស្រាល និងកណ្តាលហើយមានលក្ខណៈសម្បត្តិដូចតទៅ : ធន់ទ្រាំជំងឺ សត្វល្អិត ដើមទាប លូតលាស់កំណត់ ផ្លែច្រើននៅដើម ទុំមិនផ្ទុះមិនដួលដើម គ្រាប់ធំថ្លោស ពេញនិយមលើទីផ្សារ ជាពិសេសគឺមានគ្រាប់ច្រើនក្នុងមួយកួរៗ ២-៣គ្រាប់ ។ ជាធម្មតាក្នុង១០០គ្រាប់មានទំងន់ ៥-៧០ក្រាម ប៉ុន្តែសមស្របក្នុងទីផ្សារគឺទំងន់ ២០-៣៥ក្រាមក្នុង ១០០គ្រាប់ ។ ក្នុងនោះដែរកាលណា ១០០គ្រាប់ទំងន់លើស ពី ៣០ក្រាម គេចាត់បញ្ចូលទៅក្នុងគ្រាប់ធំ ។ ស្ថានីយក្បាលកោះបានរកឃើញពូជថ្មី ២គឺ DT ៨៤ និង AGS ៧៣ ដែរ ។

## *២- លក្ខខណ្ឌអាកាសធាតុ*

សណ្តែកសៀងរីតតែទទួលបានទិន្នផលខ្ពស់ វាត្រូវការសីតុណ្ហភាពសមស្របគឺចន្លោះពី ២២ °c-៣០ °c កាលណាទាបជាង ២០ °c និងសីតុណ្ហភាពខ្ពស់ជាង ៣២ °c មធ្យមប្រចាំថ្ងៃធ្វើឱ្យការដាក់គ្រាប់មិនបានល្អ ។ នៅប្រទេសកម្ពុជារដូវដែលសមស្របក្នុងការដាំដុះគឺអាស្រ័យទៅតាមតំបន់ដូចជា តំបន់ខ្ពង់រាប ភ្នំ គេច្រើនចាប់ផ្តើមដាំនៅ

ចុងខែកក្កដា ឬដើមខែសីហា រីឯតំបន់ទំនាបទន្លេមេគង្គ ច្រើនតែនៅរដូវរំហើយ ចាប់ពីខែតុលា វិច្ឆិកា ។ ប៉ុន្តែមានវាលរាបមួយចំនួន គេដាំប្រភេទពូជស្រាលមុន ពេលស្ទូង នៅក្នុងខែឧសភា ។

### ៣- ការជ្រើសរើស និងរៀបចំដី

សណ្តែកសៀងមានកំរិតធន់ទ្រាំទៅនឹងដីអាស៊ីតជាងសណ្តែកបាយ ឬ សណ្តែកឯទៀត ។ កាលណាដីមាន កំរិត PH ចន្លោះ៥,៥-៦,០ ក្រោយពីការដាំសណ្តែកសៀងបាន ១-២រដូវ វាធ្វើឱ្យ PH កាន់តែកើនឡើងបាន យ៉ាងឆាប់រហ័សចន្លោះពី ៦,០-៦,៥ ហើយធ្វើឱ្យទិន្នផលកាន់តែកើនឡើងជាលំដាប់ដែរ ។ ដូចនេះដីដែលឆ្លើយតប ទៅនឹងដំណាំនេះភាគច្រើនគឺប្រភេទដីល្បាយខ្សាច់ ដីឥដ្ឋមធ្យម ឬ ដីកាកសំណល់ភ្នំភ្លើង ។



ប៉ុន្តែវាមិនលូតលាស់ល្អលើប្រភេទដីឥដ្ឋធ្ងន់ ព្រោះវាមានសភាពល្អិតខ្លាំង ជ្រាបទឹកមិនរហ័សព្រោះគ្រាប់សណ្តែកមិនធន់ទ្រាំទៅនឹងសំណើមដីខ្ពស់នៅពេលដាំ ហើយមិនធ្វើឱ្យគ្រាប់អាចដុះបានល្អពេល សំណើមដីមិនគ្រប់គ្រាន់ សីតុណ្ហភាពដីប្រែប្រួលខ្លាំង ។ ដីដែលសំបូរដោយសារធាតុសរីរាង្គ ធ្វើឱ្យវាដុះលូតលាស់បានរហ័សសំបូរដោយកំពកឫស ។



សារធាតុទាំងនោះមានអាសូត (N) ផូស្វ័រ (P) ប៉ូតាស្យូម (K) កាល់ស្យូម (Ca) ម៉ាញេស្យូម (Mg) ដែក (Fe) និងស្ពាន់ធ័រ(S) មិនតែប៉ុណ្ណោះ ទិន្នផលសណ្ដែកសៀងកាន់តែកើនឡើង ។ សណ្ដែកសៀងអាចស្រូបយកជីជាតិពីដីបានខ្លាំងជាងសណ្ដែកបាយ ព្រោះប្រព័ន្ធឫសអាចលូតលាស់ទៅក្នុងជំរៅដីជាង ១សម ប៉ុន្តែ ឫសដែលមានលទ្ធភាពបង្កើតកំពកឫសច្រើនគឺស្ថិតក្នុងស្រទាប់លើជំរៅ ១០-១៥ សម ។ ដូចនេះដើម្បីឱ្យការដាំដុះទទួលបានលទ្ធផលល្អ ការរៀបចំដីវាជាផ្នែកមួយយ៉ាងសំខាន់ គឺភ្ជួររាស់ឱ្យបានជ្រៅ និងច្រើនលើកធ្វើឱ្យដីម៉ត់ រក្សាសំណើមបានល្អ បង្កឱ្យការដុះរបស់គ្រាប់ស្មើគ្នាល្អ គ្រាប់សណ្ដែកសៀងងាយរងឥទ្ធិពលរបស់កំដៅ និងសំណើមក្រោយពីរយៈពេល ៥-៦ថ្ងៃ ករណីដីផ្ដល់សំណើមមិនគ្រប់គ្រាន់ ធ្វើឱ្យគ្រាប់ពូជដុះផ្សិតមិនអាចដុះពន្លកបាន ។

## ៤- *ការដាំដុះ*

ការដាំសណ្ដែកសៀងត្រូវមានការប្រុងប្រយ័ត្នជាងដំណាំសណ្ដែកបាយដូចជាការពិនិត្យសំណើមដីជាមុន ហើយគ្រាប់ពូជត្រូវដាក់ហាលថ្ងៃឱ្យក្ដៅមុនពេលយកទៅដាំ ។ គេអាចដាំដោយម៉ាស៊ីនទំនើបដោយប្រើចន្លោះ ជួរ ៤០-៥០សម ចន្លោះគុម្ព ៣០សម ២-៣គ្រាប់ក្នុង១គុម្ព ជំរៅ ៣-៤ស.ម តែនៅប្រទេសកម្ពុជាគេដាំតាម ២

របៀបគឺ ៖

*របៀបដាំជាជួរ* ៖ គឺដាំតាមបណ្ដោយខ្សែបន្ទាត់ប្រើ ចន្លោះជួរ ៤០-៥០ ស.ម ចន្លោះគុម្ព ៣០-៤០ ស.ម ៣-៤គ្រាប់ក្នុង១គុម្ព ជំរៅ ៣-៤ស.ម ចំពោះពូជលូតលាស់កំណត់ចន្លោះជួរ និងគុម្ពសមស្រប ៤០ស.ម x ៣០ ស.ម ២-៣គ្រាប់ក្នុងមួយគុម្ព តែពូជលូតលាស់មិនកំណត់ចន្លោះជួរ និងគុម្ព ៥០ស.មX ៤០ស.ម ៣-៤ គ្រាប់ក្នុង ១គុម្ព ។

*របៀបដាំលើករង* ៖ ទទឹងរង ១០០ស.ម កំពស់រង ២៥-៣០ស.ម ដាំ ២ជួរក្នុងមួយរង ចន្លោះជួរ ៥០ស.ម ចន្លោះគុម្ព ១៥-២០ស.ម រក្សាទុក ១-២ ដើម ក្នុងមួយគុម្ព ។ ការដាំតាមរបៀបនេះងាយស្រោចស្រព ដោយបញ្ចូលទឹកតាមចន្លោះជួរពេលជួបការរាំងស្ងួត ភាគច្រើនទៅតំបន់ដែលមានប្រភពទឹក ។ ដើម្បីដាំដុះលើផ្ទៃដី ១ហ.ត គេប្រើគ្រាប់ពូជជាមធ្យម ៦៥-៧០ គ.ក្រ ចំពោះគ្រាប់ដែលមានទំងន់ ២០-២៥ក្រាម ក្នុង ១០០គ្រាប់ ។ ក្រោយពីដាំភ្លាមគេយកថ្នាំប្រឆាំងនឹងគ្រាប់ស្មៅឈ្មោះ Alachlor មកលាយទឹកបាញ់ឱ្យសព្វក្នុងចំការក៏រិត ៧០ CC ក្នុង ២០លីត្រទឹក ។

## *៥- ការស្រោចស្រព*

សណ្ដែកសៀងជាដំណាំមួយត្រូវការទឹកជាមធ្យម ។ សេចក្ដីត្រូវការទឹកចែកចេញជា ៣វគ្គៈ

- វគ្គដំណុះ និងលូតលាស់ដើមស្លឹក វាត្រូវការសំណើមជាមធ្យមហើយថេរល្មមបរិមាណទឹក ៥,៥-៦,០ ម.ម ក្នុង១ថ្ងៃសំណើមដីពី ៦០-៦២% ។



- វគ្គចេញផ្កា និងដាក់គ្រាប់ ជាវគ្គមួយដែលមិនអាចខ្វះបានកាលណាសំណើមមិនគ្រប់គ្រាន់ធ្វើឱ្យជ្រុះផ្កា ការបង្កកំណើតយឺត ដាក់គ្រាប់មិនពេញ គ្រាប់ស្លៀតច្រើន បរិមាណទឹក ៧,៦ម.ម ភាគរយសំណើមចន្លោះពី ៧០-៧៨%

- វគ្គក្តួរចាស់ និងទុំ វគ្គនេះសេចក្តីត្រូវការទឹកកាន់តែថយចុះបន្តិចម្តងៗ នៅពេលដើម ស្លឹកផ្លែ ប្រែពណ៌ បៃតងខ្ចីទៅពណ៌ស្ករ ឬ ពណ៌ដី ( បៃតងប្រផេះ) ពេលនោះសណ្តែកសៀងលែងត្រូវការសំណើមដី ។

ដូចនេះការស្រោចស្រព ត្រូវធ្វើឡើងក្នុងវគ្គដុះពន្លកលូតលាស់ដើម ស្លឹក និងជាពិសេសវគ្គចេញផ្កា និង បង្កើតក្តួរក្នុងករណីជួបការរាំងស្ងួត ។ការបញ្ចូលទឹកតាមចន្លោះជួរធ្វើឡើង ១-២លើកក្នុងមួយសប្តាហ៍ទៅតាមប្រភេទដី និងអាកាសធាតុ ។

### ៦- ការជ្រៃជ្រួយដី

ប្រយោជន៍នៃការជ្រៃជ្រួយដីគឺធ្វើឱ្យស្មៅបន្ថយការលូតលាស់ បំបាត់ជម្រកជម្ងឺសត្វល្អិត និងការប្រកួតប្រជែង ។ធ្វើឱ្យដីធូរបង្កឱ្យដីមានសំណើមល្អ សម្រួលដល់ការដុះលូតលាស់នៃប្រព័ន្ធឫសជញ្ជក់ និងការបង្កើតកំពកឫស ព្រោះកំពកឫសសណ្តែកសៀងច្រើនផ្ទុកដោយបាក់តេរីមានប្រយោជន៍ របៀបជ្រៃជ្រួយដី គឺត្រូវជ្រៃឱ្យផុសស្រទាប់លើហើយកាយប្រមូលដីពូនគល់សណ្តែកក្រោយពីដាំបានពី ១៥-២០ ថ្ងៃ ។គេអាចធ្វើឡើងដោយសម្ភារៈខុសៗគ្នាដូចជាម៉ាស៊ីនពូនគល់ ចបជំរះ ទៅតាមលទ្ធភាពដែលអាចធ្វើបាន

### ៧. ការដាក់ជី

ដើម្បីផលិតគ្រាប់សួតទំងន់ ១០០០គ.ក្រ សណ្តែកសៀងត្រូវស្រូបយកសារធាតុសំខាន់ៗពីដីមានៈ

- សារធាតុអាសូត(N) ចំនួន ៨០គ.ក្រ ប៉ុន្តែក្នុងចំនួន ៨០គ.ក្រ នេះផ្តល់ដោយការស្រូបយកពីបរិយាកាស តាមបាក់តេរី Rhyzobium ចំនួន ៥០% និងផ្តល់ដោយដី ៥០% ។

- សារធាតុផូស្វ័រ (P) ស្រូបយកពីដីផ្ទាល់មានបរិមាណពី ៨០-៩០គ.ក្រ ។

- សារធាតុប៉ូតាស្យូម (K) ស្រូបយកពីដីផ្ទាល់មានបរិមាណពី ៧៥- ៨៥ គ.ក្រ ។

ដូចនេះការប្រើប្រាស់ជីអាស្រ័យទៅតាមប្រភេទដី និងពូជ តំបន់តាមមាត់ទន្លេ គេប្រើជី ១៥ -១៥- ១៥ ចំនួនពី ២០០-២៥០ គ.ក្រ បានមុនពេលដាំហើយរាស់លុបលើផ្ទៃដី ១ហត ។ ដីវាលទំនាបមួយចំនួន គេបាចជី ១៥ -១៥- ១៥ ចំនួន ១៥០-២០០គ.ក្រ មុនពេលដាំ និងបន្ថែមជីអ៊ុយរ៉េចំនួន ៧០គ.ក្រ ពេលសណ្តែកកំពុងចេញផ្កា ។ តែប្រភេទដីក្រហមខ្ពង់រាប ប្រភេទជី ១៥- ១៥ -១៥ ចំនួន ១៥០ គ.ក្រ មុនពេលដាំ និងពេលចេញផ្កា បន្ថែមជីអ៊ុយរ៉េ ៧០គក្រ លើផ្ទៃដី១ហត ។

## III - អំពីជំងឺ និងសត្វល្អិត

### ១- អំពីជំងឺ និងវិធានការការពារ

ជារៀងរាល់ឆ្នាំ នៅក្នុងតំបន់ជាច្រើននៃទ្វីបអាស៊ី និងអាហ្វ្រិក តែងតែរងការបំផ្លាញដោយជំងឺសំខាន់ៗ ៣យ៉ាងគឺ :

- **ជំងឺច្រេះស្លឹក** បណ្តាលមកពីមេរោគ Cercospora spp ជំងឺនេះកើតនៅក្នុងលក្ខខណ្ឌ ក្តៅ សើម ជាពិសសនៅរដូវភ្លៀង ក្រោយពីសណ្តែកសៀងមានអាយុ ៤៥ថ្ងៃឡើងទៅ ដំបូងសង្កេតឃើញមានចំណុចពណ៌ត្នោតតូចៗ លើផ្ទៃស្លឹក បន្ទាប់មកចំណុចនោះកើតកាន់តែច្រើនឡើងៗ ហើយរីករាលដាលពេញផ្ទៃស្លឹក បន្ទាប់មកវាប្រែពណ៌ទៅជាពណ៌ច្រេះ ហើយស្ងួតព្រមទាំងជ្រុះ ពេលសណ្តែកកំពុងបង្កបង្កើតកួរ ឬដាក់ទឹកដោះធ្វើ ឱ្យសណ្តែកទុំមុនអាយុបាត់បង់ទិន្នផលយ៉ាងច្រើន ។

- **ជំងឺផ្សិតម្សៅលើស្លឹក ដើម ផ្លែ** បណ្តាលមកពីមេរោគ ២យ៉ាង Erysiphe Cichoracearum និង Sphoerotheca fuliginea ។ លក្ខខណ្ឌកកើតច្រើននៅរដូវត្រជាក់ស្ងួត ដំបូងលេចចេញនូវចំណុចម្សៅគ្រាប់ៗលើស្លឹក ក្រោយមកចំណុចនេះកាន់តែច្រើនឡើងពេញលើផ្ទៃស្លឹក ហើយម្សៅកាន់តែក្រាស់ បន្ទាប់មកហុយពេញចំការពេលមានខ្យល់បក់ ។ រយៈពេល១អាទិត្យស្លឹកសណ្តែកប្រែទៅជាពណ៌ត្នោត ហើយស្ងួត ជ្រុះ ធ្វើឱ្យបាត់បង់ទិន្នផលយ៉ាងខ្លាំង ។

- **ជំងឺវីរុស ឬសណ្តែកបួស** វីរុស វាបណ្តាលមកពីមេរោគក្រុម Mosaie ។ មេរោគនេះមានលទ្ធភាពជាប់មកជាមួយគ្រាប់ពូជពីមេបា បន្ទាប់មកសត្វល្អិតជាភ្នាក់ងារធ្វើការចម្លងពីដើមមួយ ទៅដើមមួយបានយ៉ាងរហ័សដូចជា Thrip . opper ឬ Aphid ។ ជំងឺនេះអាចកើតលើស្លឹកធ្វើឱ្យស្លឹកសណ្តែក ពណ៌ លឿង និងកើតលើកួរធ្វើឱ្យកួរសណ្តែកមិនដាក់គ្រាប់ជំងឺប្រភេទនេះអាចធ្វើឱ្យប៉ះពាល់ដល់ទិន្នផលសណ្តែកយ៉ាងខ្លាំងជាងជំងឺឯទៀត ។

### *វិធានការការពារ និងកំចាត់*

គឺជ្រើសរើសរដូវ ប្តូរមុខដំណាំ បំបាត់ជំរក (Host Range) ដាំឱ្យមានចន្លោះជួរ និងគុម្ពត្រឹមត្រូវ ជ្រើសរើសពូជធន់ ករណីជំងឺផ្សិត គេយកគ្រាប់ពូជមកលាយនឹងថ្នាំផ្សិតមុនដាំ និងលាយទឹកបាញ់ ៥-៧ថ្ងៃម្តងពេលពិនិត្យឃើញរោគសញ្ញាលេចឡើង ដូចជា ថ្នាំ Mancozeb,Orthocid,Zineb កំរិត ២,៥គក្រក្នុង១ហត ។ ចំពោះជំងឺបួស ត្រូវដកដើមដែលបួសនោះយកមកដុតចោល ហើយបាញ់ថ្នាំកំចាត់សត្វល្អិតជាភ្នាក់ងារចម្លងឱ្យទាន់ពេលវេលា ។

### *២- អំពីសត្វល្អិតសំខាន់ៗ និងវិធានការការពារ*

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលបំផ្លាញសណ្តែកទាំងស្លឹក ដើម ផ្កា ផ្លែ និងគ្រាប់ ។

- ដង្កូវហ្វូង Armyworm Spodoptera spp

- លំដាប់ Lepidoptera , គ្រួសារ Noctuidae មេអំបៅពងដាក់លើផ្ទៃស្លឹក មានស្បែពណ៌ទឹកប្រាក់គ្របការពារពង មេអំបៅមួយអាចពងពី ២៥-៥០០ ពង រយៈពេល៣ថ្ងៃវានឹងញាស់ហើយចាប់ផ្តើមស៊ីបំផ្លាញ ។ វគ្គជាដង្កូវមាន ២០-៤៦ ថ្ងៃហើយដឹកឌឿ ៨-១១ ថ្ងៃ សរុបវដ្តជីវិតមាន ៣០-៦១ថ្ងៃ ។ ដង្កូវប្រភេទនេះស៊ីស្លឹក ផ្កាក្ងរខ្ចីៗ មានលក្ខណៈជាហ្វូង ។

- ដង្កូវកាត់ដើម Black cutworm Agrotis ipsilon លំដាប់ Lepidotera គ្រួសារ Noctuidae មេអំបៅពងដាក់លើស្មៅ ឬស្លឹកដំណាំ រយៈពេល ២ថ្ងៃទៅ ២អាទិត្យ

ទើបញាស់អាស្រ័យដោយលក្ខខណ្ឌធាតុអាកាស និងចំណីអាហារ ។ ដង្កូវអាចបន្សាំខ្លួនបាន២អាទិត្យទៅ ៥ខែ ដឹកឡើបន្សាំជីវិតនៅក្នុងដីរយៈពេលពី ១-៨ អាទិត្យ ។ វាបំផ្លាញដោយកាត់ដើមសណ្ដែកក្នុងវគ្គដុះពន្លក និងលូតលាស់ដំបូង ។

- ដង្កូវស៊ីរូងកួរ Bean Podbore Marucatestulalis លំដាប់ Lepidoptera គ្រួសារ Pyralidae មេអំបៅពងដាក់លើស្មែងផ្កា ឬស្លឹកក្បែរទងផ្កា ពេលខ្លះរាយប៉ាយពេលខ្លះផ្តុំគ្នា ។ ក្រោយពីពងរយៈពេល ២-៤ថ្ងៃ វា នឹងញាស់ក្រោយពីញាស់ហើយវាចោះស៊ីផ្កា ឬកួរសណ្ដែកខ្ចីៗ មានរយៈពេល ១០ថ្ងៃ ក្រោយពីបញ្ចប់វគ្គជាដង្កូវវា ក្លាយទៅជាដឹកឡើនៅក្នុងកួរ ឬរមូរ ស្លឹកចំនួន ៦ថ្ងៃ ក្រោយមកវាញាស់ទៅជាមេអំបៅវិញ ។ វដ្ដជីវិតសរុបរបស់ វាមាន ១៨-២០ថ្ងៃ ។ លក្ខខណ្ឌដែលធ្វើឱ្យវាកើត និងបំផ្លាញជាលក្ខណៈធ្ងន់ធ្ងរគឺនៅរដូវក្ដៅ ចាប់ពីខែកុម្ភៈ ដល់ខែមិថុនា នៅប្រទេសកម្ពុជា ។

- ស្រើងខ្លួនវែង ឬស្រើងពណ៌ត្នោត លំដាប់ Hemiptera គ្រួសារ Coreidae ។ មេចំណាស់របស់ស្រើងពងដាក់លើដើម ស្លឹក ទងផ្កាឬលើកួរ មានលក្ខណៈរាយៗ ក្រោយពីពងរយៈ ពេល ៥-៧ថ្ងៃ វានឹងញាស់ហើយចោមជញ្ជក់កួរសណ្ដែករយៈពេល ២អាទិត្យ វាបានសកចូលទៅដំណាក់កាលទី ២ លក្ខណៈបំផ្លាញដដែល ប៉ុន្តែមិនផ្តុំគ្នារយៈពេល ១អាទិត្យ វាក៏បានសកចូលទៅមេចំណាស់ដំណាក់កាលទី ៣ ។ រយៈពេលនៃមេចំណាស់មានរហូតដល់ ៣ - ៤ ខែ ការបំផ្លាញរបស់វាគឺធ្វើឱ្យគ្រាប់សណ្ដែក

ស្លៀត ករណីផលិតពូជធ្វើឱ្យគ្រាប់ពូជដុះខ្សោយនៅ ជំនាន់បន្ទាប់ ។

- ស្រីងបៃតង ឬស្រីងខ្លួនខ្លី លំដាប់ Hemiptera គ្រួសារ Pentatomidae ។ មេស្រីងតែងពងដាក់លើដើម ស្លឹក លក្ខណៈតំរៀបជួរផ្តុំគ្នា រយៈពេល ២-៣ ថ្ងៃ វាញាស់ ក្រោយពីញាស់ហើយវាបន្តសកចំនួន៥ដំណាក់កាលក្នុងរយៈពេល ១៥-៣០ ថ្ងៃ ហើយក្លាយជាមេស្រីង។ ដូចនេះវដ្តជីវិតមាន ២៣-៣៣ ថ្ងៃ ។

- ចៃបៃតង

- លំដាប់ Homoptera

- គ្រួសារ Aphididae



មេរបស់ថៃបង្កើតហ្វូងថៃបានយ៉ាងច្រើនក្នុង ១ឆ្នាំៗ នៅតំបន់អាកាសធាតុក្តៅ ។ មេមួយឱ្យកំណើតកូនថៃបានជាមធ្យមក្នុង១ថ្ងៃគឺ ១៥កូនថៃ ។ សរុបអាយុកាលរបស់វាគឺបាន ២ខែ ។ ទាំងកូនញាស់ និងមេចំណាស់អាចបំផ្លាញដំណាំដោយជញ្ជក់ជាក្រុមៗ។ ក្រោយពីបំផ្លាញ ធ្វើឱ្យដំណាំទទួលរងនូវប្រភេទជំងឺវីរុស គេអាចដឹងអំពីវត្តមានថៃនៅក្នុងចំការដំណាំដោយសារក្រុមស្រមោច ដែលទៅចោមជញ្ជក់យកទឹកដមសំណល់ពីថៃ ។

-មម៉ង់ជញ្ជក់សណ្តែក លំដាប់ Thysanoptera គ្រួសារ Thripidae ទ្រីពប្រភេទនេះខុសពីទ្រីពពង បញ្ចូលទៅក្នុងជាលិកានៃស្លឹកសណ្តែក បន្ទាប់មកញាស់មកវាចាក់នឹង មាត់ហើយជញ្ជក់ជាពិសេសស្លឹកខ្ចីៗ នឹងផ្កាសណ្តែកធ្វើឱ្យ ស្លឹកសណ្តែកស្ងួត ជ្រុះផ្កា វដ្តជីវិតរបស់វា ៣-៥ អាទិត្យ ប៉ុន្តែកាលណាសីតុណ្ហភាព ២០ °c វាអាចបន្តជីវិតបានវែង ហើយបង្កើតកូនបានច្រើនជំនាន់ ។

-មមាចជញ្ជក់ស្លឹក លំដាប់ Homopera គ្រួសារ Cicadellidae ។ វាពងរាយៗ ដាក់លើផ្ទៃស្លឹកដោយបញ្ចូលទៅក្នុងជាលិកានៃស្លឹក រយៈពេល ៦-៧ថ្ងៃ វានឹងញាស់ហើយចាប់ផ្តើមជញ្ជក់ស្លឹកសណ្តែក ក្រោយមកបន្តសកចំនួន ៤លើកទៅជាមមាច ។ វដ្តជីវិតសរុបមាន ១១-១៧ ថ្ងៃ វាជាភ្នាក់ងារចម្លងវីរុសបានច្រើនប្រភេទ ។

- ខ្មូតស៊ីគ្រាប់ពូជ Bruchid Callosobruchus chinensis លំដាប់ Coleoptera គ្រួសារ Bruchidae ។ មេខ្មូតញីពងដាក់លើក្ដួរសណ្តែកទុំដោយបញ្ចូលពងទៅក្នុង

គ្រាប់សណ្តែក ឬពងដាក់គ្រាប់សណ្តែក ក្រោយពេល ប្រមូលផល ។ វដ្តជីវិតមានរយៈពេល ១ខែ ឬតិចជាង ប៉ុន្តែវាអាចបន្តជំនាន់របស់វាបានច្រើនដងក្នុងមួយឆ្នាំ។

*វិធានការការពារ និងកំចាត់*

ដើម្បីការពារ និងកំចាត់សត្វល្អិត គេអនុវត្តបានច្រើនវិធីសាស្ត្រដូចជា ការជ្រើសរើសរដូវ រៀបចំដីឱ្យ បានល្អដាំតាមបច្ចេកទេស (គុម្ព - ជួរ) កំចាត់ស្មៅ ជ្រើសរើសពូជធន់ទ្រាំ ។



## IV - ការប្រមូលផល

ការប្រមូលផលសម្រាប់ទុកពូជ និងផលិតកម្មមានការខុសគ្នាគឺៈ

### ១- របៀបប្រមូលផលពូជ

នៅក្នុងចំការទាំងមូល គេត្រូវកំណត់ផ្ទៃដីជាក់លាក់មួយសម្រាប់ច្រូតធ្វើពូជ ដូចនេះពេលសណ្តែកចេញផ្កា គប្បីធ្វើការជម្រើសតាមលំដាប់លំដោយដូចជា ៈដកចោលដើមកើតជម្ងឺ ដើមដែលមានលក្ខណៈខុសគេ ពណ៌របស់ផ្កា កម្ពស់ដើម ទម្រង់ស្លឹក ពណ៌ដើម ស្លឹក កាលណាលេចចេញនូវភាពប្លែកត្រូវដកចោល ។ ក្នុងដំណាក់កាលទុំនៃកួរ ជម្រើសម្តងទៀតពេលអាយុកាលទុំស្មើគ្នា ពណ៌នៃកួរទុំ ទម្រង់គ្រាប់ ពណ៌នៃកួរស្លឹក ដើមខុសប្រភេទត្រូវដកចោល បន្ទាប់មកច្រូតយកដើមមកហាលថ្ងៃឱ្យស្ងួត ( មិនត្រូវពន្យារពេលក្នុងការសម្រិតសម្រាំងគ្រាប់ពូជឡើយ) វាយថ្នមៗ បំបែកសំបក សំអាតគ្រាប់ព្រមទាំងបន្តការហាលរយៈពេល ២-៣ថ្ងៃ និងជម្រើសយកគ្រាប់សុទ្ធម្តងទៀតគឺយកគ្រាប់មានលក្ខណៈឯកសណ្ឋានទើបទុកដាក់បាន ។









## ២- របៀបប្រមូលផលលក្ខណៈផលិតកម្ម

នៅពេលសណ្តែកទុំ ៨៥% ត្រូវច្រូតដើមសណ្តែកមកដាក់ហាលថ្ងៃឱ្យស្ងួតរយៈពេល ២-៣ ថ្ងៃ បន្ទាប់មកវាយសម្រាំងយកគ្រាប់ ព្រមទាំងសំអាតដោយជ្រើសយកចេញនូវគ្រាប់ស្អុយ ឬដង្កូវស៊ីហើយបន្តការហាលរយៈពេល ១ថ្ងៃបន្តទៀត ដើម្បីឱ្យសំណើមគ្រាប់ស្ថិតក្នុងកម្រិតស្តង់ដាជាក់លាក់ ១៤-១៥% ទើបទុកបាន ។ អាយុកាលនៃការប្រមូលផលទៅតាមប្រភេទពូជ ពូជស្រាល ជាមធ្យម ៧០ថ្ងៃ ពូជកណ្តាល ៨៥-៩០ ថ្ងៃ និងពូជធ្ងន់ ១១០-១២០ថ្ងៃក្រោយដាំ ។ ជាទូទៅទិន្នផលសណ្តែកសៀងក្នុងទ្វីបអាស៊ី ជាពិសេសអាស៊ីខាងកើតទិន្នផលមធ្យម ១០៧៣ គក្រ/១ហាត នៅប្រទេសកម្ពុជាបច្ចុប្បន្នពូជ B ៣០៣៩ ដែលកសិករដាំដុះនៅក្នុងខេត្តកំពង់ចាម ៨៥៥ គក្រ/១ហាត ។ ចំពោះពូជថ្មីដែលទើបជម្រើសបានដូចជា DT ៨៤ និង AGS ៧៣ ទទួលទិន្នផលមធ្យម ១៤៥០ គក្រ/ហ.ត ។

